**ឯកសារសង្ខេប**

គណៈកម្មការទី១ ព្រឹទ្ធសភា ទទួលបន្ទុកសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត

# ការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុង ប្រទេសកម្ពុជា និងប្រទេសហ្វីលីពីន

**អ្នកស្រាវជ្រាវ៖** លោក **ខាំ វ៉ាន់ដា**

លោកស្រី **ស៊ូ សោភា**

ខែកក្កដា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


**១. សេចក្តីផ្តើម ...... 1**

**២. យន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា ...... 1**

២ ១.តួអង្គ និងស្ថាប័នរដ្ឋាភិបាលសំខាន់ៗពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា ...... 1

២អត្ថប្រយោជន៍ និង ២.បញ្ហាប្រឈមនានានៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ...... 6

**៣. ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសហ្វីលីពីន ...... 7**

៣ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ១. ...... 7

៣យន្តការរបស់រដ្ឋាភិបាល ២. ...... 8

**៤. សេចក្តីសន្និដ្ឋាន ...... 10**

**គន្ថនិទ្ទេស ...... 12**

## ១. សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជា ករណីវិវាទដីធ្លីត្រូវបានដោះស្រាយទាំងតាមរយៈប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ។ ពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា គណៈកម្មការសុរិយោដីបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការដោះស្រាយទំនាស់ដីធ្លីទាំងឡាយ ចាប់តាំងពីគណៈកម្មការនេះបង្កើតឡើងក្នុងឆ្នាំ២០០២។ លើសពីនេះ គេសង្កេតឃើញមាន តួអង្គ និងស្ថាប័នរដ្ឋាភិបាលនានាដែលពាក់ព័ន្ធក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការផងដែរ។

ឯកសារសង្ខេបនេះ នឹងផ្តល់នូវការពិព៌ណ៌នាដោយសង្ខេបទៅលើ យន្តការនានានៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា និងប្រទេសហ្វីលីពីន។

## ២. យន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា

ក្រៅពីការដោះស្រាយវិវាទនានាតាមរយៈប្រព័ន្ធតុលាការ គេចាត់ទុកថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (Alternative Dispute Resolution “ADR”) ជាវិធីសាស្ត្រមួយទៀតដើម្បីប្រើប្រាស់សម្រាប់ដោះស្រាយវិវាទនានាផងដែរ។ នេះគឺជាយន្តការដោះស្រាយមួយដែលប្រជាជនអាចប្រើប្រាស់ជាជម្រើសមួយដើម្បីដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ។[1] ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយ វិវាទគ្រួសារ ជម្លោះជាមួយអ្នកជិតខាង និងវិវាទបរិស្ថាន ពាណិជ្ជកម្ម និង ឧស្សាហកម្ម។[2] ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការមានជាច្រើនទម្រង់ ហើយទម្រង់ដែលត្រូវបានគេស្គាល់ជាទូទៅគឺតាមរយៈការចរចារ ការផ្សះផ្សា សន្ទានកម្ម និងមជ្ឈត្តកម្ម។[3] *សូមមើលឯកសារស្រាវជ្រាវដែលភ្ជាប់មកជាមួយឯកសារសង្ខេបនេះ ដែលមានចំណងជើងថា«ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ» សម្រាប់ការពន្យល់បន្ថែមទៅលើទម្រង់ទាំងនេះ ចាប់ពីទំព័រ ២ រហូតដល់ទំព័រ ៦។*

### ២.១ តួអង្គ និងស្ថាប័នរដ្ឋាភិបាលសំខាន់ៗ ពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា

គេសង្កេតឃើញថា ក្នុងប្រទេសកម្ពុជានៅពេលមានករណីជម្លោះដីធ្លី ភាគីជម្លោះនានាហាក់បីដូចជាស្វះស្វែងរកតួអង្គឬស្ថាប័នសំខាន់ៗមួយចំនួនដើម្បីជួយដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការដូចខាងក្រោម៖

---

[1] Steven Austermiller, “Cambodian Alternative Dispute Resolution,” in The Introduction to Law (Konrad-Adenauer-Stiftung, 2012), 183, accessed on June 08, 2015, URL: http://www.kas.de/wf/doc/kas_31083-1522-1-30.pdf?120720080906

[2] Melissa Lewis and Les McCrimmon “The Role of ADR Process in the Criminal Justice System: A view from Australia” ( Paper presented at At ALRAESA Conference, Entebbe, Uganda 4-8 September, 2005), 2 accessed on June 08, 2015, URL: http://www.justice.gov.za/alraesa/conferences/2005uganda/ent_s3_mccrimmon.pdf

[3] Austermiller, “Cambodian Alternative Dispute Resolution,” 183

**(i) សហគមន៍**

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានចាក់ឫសនៅក្នុងទំនៀមទម្លាប់របស់ប្រទេសកម្ពុជា[4] ដែលជម្លោះជាច្រើនជាធម្មតាត្រូវបានដោះស្រាយដោយផ្អែកលើវប្បធម៌ និងការអនុវត្តន៍តាមតំបន់។[5] ជាឧទាហរណ៍ ចាស់ទុំនៅក្នុងភូមិ ឬប្រធានភូមិត្រូវបានគេសុំការជួយគាំទ្រដើម្បីដោះស្រាយវិវាទទាំងឡាយនៅក្នុងភូមិ។ ការអនុវត្តន៍នេះ ត្រូវបានគេហៅថាជាការ «សម្រុះសម្រួល ឬផ្សះផ្សា»។[6] *សូមមើលឯកសារស្រាវជ្រាវភ្ជាប់មកជាមួយឯកសារសង្ខេបនេះ ដែលមានចំណងជើងថា «ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ» សម្រាប់ការពន្យល់បន្ថែមទៅលើបទពិសោធន៍ជាប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងការដោះស្រាយវិវាទនៅក្នុងប្រទេសកម្ពុជា ចាប់ពីទំព័រ ៦ រហូតដល់ទំព័រ ១១។*

យោងតាមការអង្កេតមួយ ដែលបានសិក្សាដោយ មូលនិធិអាស៊ី ដែលមានចំណងជើងថា៖«ក្រុមប្រឹក្សាឃុំនៅក្នុងប្រទេសកម្ពុជា៖ ការអង្កេតថ្នាក់ជាតិ ស្តីពី មុខងារ និងការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ ដោយផ្តោតលើការដោះស្រាយជម្លោះនៅក្នុងឆ្នាំ២០០៥» បានបង្ហាញថា ប្រធានភូមិ គឺជាអ្នក ដែលត្រូវបានគេរកឲ្យជួយដោះស្រាយវិវាទដីធ្លីទ្រង់ទ្រាយតូចច្រើនជាងគេបំផុត។[7] ក្រុមប្រឹក្សាឃុំ គឺជាអ្នកទីពីរដែលត្រូវបានគេរកឲ្យជួយដោះស្រាយវិវាទដីធ្លី ចំណែកឯអ្នកបន្ទាប់គឺចាស់ព្រឹទ្ធាចារ្យទាំងឡាយនៅក្នុងភូមិ។ តួអង្គទាំងនេះ ចូលរួមដោះស្រាយវិវាទដីធ្លីទ្រង់ទ្រាយតូច[8] ក្នុងនាមជាសន្ធានការី (mediator)/អ្នកផ្សះផ្សា(conciliator)។ ទោះបីជាយ៉ាងណាក៏ដោយ ហាក់ដូចជាមិនមែនព័ត៌មានច្រើនពាក់ព័ន្ធនឹង ចំនួនករណីវិវាទដីធ្លី ដែលដោះស្រាយបានជោគជ័យដោយតួអង្គទាំងនេះឡើយ។

**(ii) អង្គការសង្គមស៊ីវិល**

ថ្មីៗនេះ អង្គការមិនមែនរដ្ឋាភិបាល ADHOC បានចូលរួមក្នុងការដោះស្រាយវិវាទដីធ្លីនានា។ អង្គការនេះ បានបង្កើតនូវកម្មវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR)[9] ដើម្បីចូលរួមចំណែក

---

[4] Kong Phallack, “Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform”, in The Introduction to Cambodian Law, ( Konrad-Adenauer-Stiftung, 2012) p. 12, accessed on June 08, 2015, URL: http://www.kas.de/wf/doc/kas_31083-1522-1-30.pdf?120720080906

[5] Yrigoyen Fajardo, Kong Rady and Phan Sin, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples*, (2005), p. 1.

[6] Ian Ramage,et all *Somroh Somruel& Violence Against Women, (* Domrei Research and Consulting, 2008) p. 1-4.

[7] The Asia Foundation, Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution, by Kim Ninh and Roger Henke, (2005), p.45, accessed on June 22, 2015, URL: https://asiafoundation.org/resources/pdfs/CBCCSurvey.pdf

[8] ឧទាហរណ៍មួយពាក់ព័ន្ធនឹង វិវាទដីធ្លីទ្រង់ទ្រាយតូចនៅក្នុងបរិបទនេះ គឺសំដៅលើ ជម្លោះបែងចែកព្រំដី យោងទៅតាម The Asia Foundation, Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution, by Kim Ninh and Roger Henke, (2005), p.11

[9] កម្មវិធីនេះ ទទួលបាននូវការគាំទ្រដោយសហគមន៍អឺរ៉ុប និង ម្ចាស់ជំនួយអន្តរជាតិផ្សេងទៀត យោងតាម “Result of ADR Section in 2013,” ADHOC, accessed on June 22, 2015, URL: http://www.adhoc-cambodia.org/?p=4374

ក្នុងការដោះស្រាយវិវាទទ្រង់ទ្រាយតូចតាំងពីឆ្នាំ២០១៣ មកម្លេះ។ អង្គការនេះ បានផ្តល់នូវសេវាកម្មនានាដែលមានលក្ខណៈ អាព្យាក្រឹត្យ មិនយកកម្រៃ និងសេវាកម្មសន្ធានកម្មដែលផ្អែកលើមូលដ្ឋានសិទ្ធិមនុស្សនានា។[10] នៅចន្លោះឆ្នាំ ២០១៣ និង២០១៤ អង្គការ ADHOC បានទទួលពាក្យបណ្តឹងវិវាទចំនួន ១៥៧ករណី[11] ដែលករណីភាគច្រើនពាក់ព័ន្ធទៅនឹងជម្លោះនៅក្នុងគ្រួសារ ឬជម្លោះដីធ្លី។ ជាលទ្ធផលនៃដំណើរការសន្ធានកម្មរបស់ខ្លួន សន្ធានការី (mediators) របស់អង្គការ ADHOC បានជួយភាគីជម្លោះទាំងឡាយឲ្យឈានទៅរកកិច្ចព្រមព្រៀង ដែលមានចំនួនប្រមាណជា ៧0% នៃចំនួនករណីវិវាទសរុប។[12]

ទោះបីជាយ៉ាងណាក៏ដោយ ហាក់ដូចជាមិនមានព័ត៌មានដែលអាចរកបាន ចំពោះចំនួនជាក់លាក់នៃករណីវិវាទដីធ្លីនានា ដែលត្រូវបានធ្វើសន្ធានកម្ម/ធ្វើការផ្សះផ្សាដោយអង្គការ ADHOC ឡើយ។ បើទោះជាយ៉ាងនេះក៏ដោយ អង្គការ ADHOC បានរៀបចំចងក្រងនូវករណីសិក្សាមួយចំនួន ដែលពាក់ព័ន្ធទៅនឹងរបៀប ដែលអង្គការរបស់ខ្លួនធ្វើសន្ធានកម្ម/ធ្វើការផ្សះផ្សាដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។[13] គួរកត់សម្គាល់ផងដែរថា អង្គការ ADHOC ព្យាយាម ដោះស្រាយវិវាទដីធ្លីដែលមានលក្ខណៈទ្រង់ទ្រាយតូច រវាងអ្នកភូមិ និងអ្នកភូមិតែប៉ុណ្ណោះ។

### (iii) ស្ថាប័នរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយន្តការស្ថាប័ននានាដើម្បីដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ដែលមានចាប់ពីថ្នាក់ក្រោមជាតិទៅដល់ថ្នាក់ជាតិ។ យន្តការទាំងនេះ រួមមានដោយសង្ខេប (សូមមើលឯកសារស្រាវជ្រាវដែលភ្ជាប់មកជាមួយស្រាប់ស្តីពី «ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ» សម្រាប់ការពន្យល់បន្ថែម ទៅលើស្ថាប័នទាំងនេះ ចាប់ពីទំព័រ១១ ទៅដល់ទំព័រ២២)៖

- **គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់៖** គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងដោយឃុំ-សង្កាត់ នៅក្នុងឆ្នាំ២០០៦។ តួនាទីមួយក្នុងចំណោមតួនាទីទាំងឡាយរបស់គណៈកម្មាធិការនេះ គឺធ្វើសន្ធានកម្ម/ធ្វើការផ្សះផ្សាជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការ ប្រសិនបើភាគីយល់ស្របទៅនឹងដំណើរការទាំងនេះ។[14] ប៉ុន្តែ តាមមតិរបស់កម្មវិធីអភិវឌ្ឍន៍អង្គការ

---

[10] "Result of ADR Section in 2013," ADHOC, accessed on June 22, 2015, URL: http://www.adhoc-cambodia.org/?p=4374

[11] ករណីវិវាទទាំងនោះរួមមាន៖ វិវាទដីធ្លី វិវាទកិច្ចសន្យា វិវាទកេរ្តិ៍មរតក ជម្លោះគ្រួសារ ជម្លោះអាពាហ៍ពិពាហ៍ ជម្លោះទ្រព្យសម្បត្តិ និងជម្លោះផ្សេងៗ។

[12] Ibid.

[13] "Land Disputes- A Case of Alternative Dispute Resolution in Banteay Meanchey Province," ADHOC, accessed on June 22, 2015, URL: http://www.adhoc-cambodia.org/?p=2973; See also "ADHOC Successfully Mediates in Longstanding Land Dispute at Srechar Commune, Snoul District, Kratie Province," ADHOC, accessed on June 22, 2015, URL: http://www.adhoc-cambodia.org/?p=3437

[14] UNDP-Cambodia Operation manual for commune dispute resolution committee (CDRC), (UNDP-Cambodia 2010) p.1. URL: http://www.un.org.kh/undp/media/files/OperationsmanualforCommuneDisputeResolutionCommittee_Eng.pdf.

សហប្រជាជាតិ (UNDP) បង្ហាញថា មានករណីជម្លោះដីធ្លីមួយចំនួន មិនគួរធ្វើការផ្សះផ្សា ដោយគណៈកម្មាធិការនេះទេ។ ករណីជម្លោះដីធ្លីទាំងនោះរួមមាន៖ ជម្លោះដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិ វិវាទដែលភាគីមិនយល់ព្រមដោះស្រាយដោយសន្ធានកម្ម/ការផ្សះផ្សា និង វិវាទដែលសន្ធានការី ឬ អ្នកផ្សះផ្សាពាក់ពន្ធ័ក្នុងរឿងទំនាស់បណ្តាលឲ្យមានទំនាស់ផលប្រយោជន៍ជាមួយនឹងភាគីវិវាទ។[15] គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ បានទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងវិវាទដីធ្លីចំនួន ៤០៤ករណី ចាប់តាំងពីគណៈកម្មាធិការនេះបង្កើតរហូតដល់ឆ្នាំ២០១៣។[16] ទោះបីជាយ៉ាងណាក៏ដោយ មិនមានព័ត៌មានជាក់លាក់ពាក់ព័ន្ធនឹងចំនួនករណីជម្លោះដីធ្លី ដែលបានដោះស្រាយដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់នេះទេឡើយ។ សូមមើលឧបសម្ព័ន្ធទី១ ស្តីពី បញ្ជីឈ្មោះសមាជិកគណៈកម្មាធិការដោះស្រាយវិវាទឃុំ-សង្កាត់។

- **មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ៖** ស្ថាប័ននេះ ត្រូវបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដែលមានតួនាទីមួយចំនួនរួមមាន៖ (១) ផ្តល់នូវការបណ្តុះបណ្តាល និង/ឬ ការប្រឹក្សាបច្ចេកទេសជូនទៅឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់លើផ្នែកការផ្សះផ្សា រួមទាំងបញ្ហាផ្នែកច្បាប់មួយចំនួន (២) ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការព័ត៌មានផ្នែកច្បាប់នៅថ្នាក់ស្រុក និងឃុំ (៣) ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ចាំបាច់ដល់សាធារណៈជននៅមូលដ្ឋាន (៤) ធ្វើការផ្សះផ្សា និងធ្វើសន្ធានកម្មវិវាទក្នុងករណីមានការស្នើសុំពីភាគី (៥) ផ្តល់សេវាពិគ្រោះយោបល់ និងចង្អុលផ្លូវដល់ភាគីនៃវិវាទដែលមិនទាន់បានដោះស្រាយនៅថ្នាក់មូលដ្ឋាននៅឡើយ។[17] ចាប់តាំងពីការបង្កើតមណ្ឌលនេះរហូតដល់ឆ្នាំ២០១៣ មណ្ឌលសេវាកម្មយុត្តិធម៌ក្រុងស្រុកខណ្ឌបានទទួលសំណុំរឿងវិវាទដីធ្លី ចំនួន៤៨៩ករណី។[18] ប៉ុន្តែ មិនមានព័ត៌មានជាក់លាក់ពាក់ព័ន្ធនឹងចំនួនករណីជម្លោះដីធ្លីដែលបានដោះស្រាយ ដោយមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌនេះឡើយ។

- **គណៈកម្មការសុរិយោដី៖** គណៈកម្មការសុរិយោដី មានបីថ្នាក់រួមមាន៖ (១) គណៈកម្មការសុរិយោដី ថ្នាក់ក្រុង/ស្រុក/ខណ្ឌ (MDKCC) (២) គណៈកម្មការសុរិយោដី ថ្នាក់ខេត្ត និងរាជធានី (CPCC) និង (៣) គណៈកម្មការសុរិយោដីថ្នាក់ជាតិ(NCC)។ គណៈកម្មការសុរិយោដីមានសមត្ថកិច្ចធ្វើការដោះស្រាយរាល់ជម្លោះដីធ្លីដែលមិនបានចុះបញ្ជី។[19] ជាទូទៅ គណៈកម្មការសុរិយោដីនៅគ្រប់កម្រិតទាំងអស់មានតួនាទីជា សន្ធានការី/អ្នកផ្សះផ្សាដើម្បី

[15] Ibid, 17
[16] Ministry of Justice, Report to the Minister of the Ministry of Justice, No. 02 STY/14 dated January 14, 2014.
[17] Inter-ministerial Prakas No. 85Rbk/MOJ/MOI/06, Article 3.
[18] Ministry of Justice, Report to the Minister of the Ministry of Justice, No. 02 STY/14 dated January 14, 2014.
[19] Sub Decree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002.

ដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។ ចំពោះគណៈកម្មការសុរិយោដីថ្នាក់ខេត្ត និងរាជ-ធានី (CPCC) ព្រមទាំងគណៈកម្មការសុរិយោដីថ្នាក់ជាតិ (NCC) គណៈកម្មការសុរិយោដីនៅថ្នាក់ទាំងពីរនេះ មានអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្តចំពោះករណីវិវាទដីធ្លីទាំង-ឡាយណា ដែលមិនអាចដោះស្រាយបាននៅថ្នាក់ក្រោម។ ហើយគណៈកម្មការសុរិយោដីនៅថ្នាក់ទាំងពីរនេះ ក៏មានសមត្ថកិច្ចពេញលេញនៅក្នុងការសម្រេចថាអ្នកណាគឺជាម្ចាស់កម្មសិទ្ធិករនៅលើដីឬអ្នកមានកម្មសិទ្ធិពេញច្បាប់។[20]ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការសម្រេចចិត្តជាលាយលក្ខអក្សរ ហើយភាគីមិនពេញចិត្ត ភាគីទាំងនេះអាចស្នើសុំទៅតុលាការដើម្បីពិនិត្យឡើងវិញក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីទទួលនូវសេចក្ដីសម្រេចនោះ។[21] ចាប់តាំងពីខែមេសា ឆ្នាំ២០០៣ រហូតដល់ចុងខែមេសា ឆ្នាំ២០១៤ គណៈកម្មការសុរិយោដី នៅគ្រប់កម្រិតទាំងអស់បានទទួលសំណុំរឿងចំនួន ៦២២៤ ករណី និងបានដំណើរការសំណុំរឿងចំនួន ៥៣៧០ ករណីនៃសំណុំរឿងដែលទទួលបាន។ ក្នុងចំណោមសំណុំរឿងដែលបានដំណើរការសំណុំរឿងចំនួន ២៧៤២ ករណី ត្រូវបានផ្សះផ្សាដោយជោគជ័យ។[22]

- **អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី**

  នៅក្នុងឆ្នាំ ២០០៦ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី។ អាជ្ញាធរនេះ មានភារកិច្ចដោះស្រាយទំនាស់ដីធ្លីទាំងអស់ដែលនៅក្រៅសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។[23] នៅពេលបច្ចុប្បន្ន អាជ្ញាធរនេះ ដឹកនាំដោយឧបនាយករដ្ឋមន្ត្រីមួយរូប ព្រមទាំងរួមមាន ២៦ ក្រសួង ឬស្ថាប័នដែលជាសមាជិក។[24] ចាប់តាំងពីពេលបង្កើតរហូតដល់ឆ្នាំ ២០១០ អាជ្ញាធរនេះ បានទទួលសំណុំរឿងចំនួន ១៤២១ ករណី។ ក្នុងចំណោមករណីទាំងនេះ អាជ្ញាធរជាតិនេះបានដោះស្រាយ ចំនួន ២២៥ ករណី (១៥,៨៣%) និង សំណុំរឿងចំនួន ១០៤៣ ករណី (៧៣,៣៩%) ត្រូវបានបញ្ជូនទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដោះស្រាយ ខណៈដែលសំណុំរឿងចំនួន ១៥៣ ករណី (១០,៧៦%) មិនទាន់ត្រូវបានដោះស្រាយ។[25]

គេសង្កេតឃើញថា មានការលំបាក ក្នុងការអះអាងថា តួអង្គ និងស្ថាប័នរដ្ឋាភិបាលមួយណា ដែលជាតួអង្គ ឬស្ថាប័នដែលមានប្រសិទ្ធិភាពជាងគេបំផុត ក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ នៅក្នុងប្រទេសកម្ពុជា ពីព្រោះថា ហាក់ដូចជាមិនមានការសិក្សាស្រាវជ្រាវជាក់លាក់ទៅលើប្រសិទ្ធិភាពនៃតួអង្គ ឬស្ថាប័ន

---

[20] Sub Decree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002, Article 19 and 20.
[21] Ibid, Article 23
[22] Ibid, p.4
[23] Royal Decree on Establishment of National Authority to Settle Land Dispute, NS/RKT/0206/097 February 26 2006, Article 3
[24] NGO Forum, *Statistical Analysis of Land Disputes in Cambodia* (Phnom Penh, 2013), 5.
[25] GIZ Land Right Program II, Presentation during TWG Land DP meeting, Ausgust 2014 as cited in NGO Forum, *Statistical Analysis of Land Disputes in Cambodia* (Phnom Penh, 2013), 5.

នីមួយៗនៅក្នុងការដោះស្រាយជម្លោះដីធ្លីនោះទេ។ លើសពីនេះទៀត មានហេតុផលមួយចំនួន ដែលទំនងបញ្ជាក់ពីមូលហេតុដែលថា វាមានការលំបាក ក្នុងប្រៀបធៀបពីប្រសិទ្ធិភាពនៃតួអង្គ ឬស្ថាប័ននីមួយៗក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។ មូលហេតុមួយក្នុងចំណោមមូលហេតុនានា គឺថា តួអង្គ ឬស្ថាប័នរដ្ឋាភិបាលនីមួយៗ(ឧ. គណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី) មានសមត្ថកិច្ចផ្សេងៗគ្នា ដែលអនុញ្ញាតឲ្យតួអង្គ ឬស្ថាប័នទាំងនោះនូវសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដីធ្លីនានា។ ឧទាហរណ៍ គណៈកម្មការសុរិយោដី ដោះស្រាយវិវាទដីធ្លីណាដែលមិនមានប័ណ្ណកម្មសិទ្ធិ ឬមិនបានចុះបញ្ជីតែប៉ុណ្ណោះ ចំណែកឯ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី មានតួនាទី ក្នុងការដោះស្រាយជម្លោះដីធ្លីណាដែលនៅក្រៅពីសមត្ថកិច្ច របស់គណៈកម្មការសុរិយោដី។ មូលហេតុផ្សេងទៀត គឺថា តួអង្គ ឬស្ថាប័ននីមួយៗត្រូវបានបង្កើតឡើងនៅក្នុងរយៈពេលផ្សេងគ្នា។ ឧទាហរណ៍ គណៈកម្មការសុរិយោដី ត្រូវបង្កើតឡើងក្នុងឆ្នាំ ២០០២ ចំណែកឯ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី បានបង្កើតឡើងក្នុងឆ្នាំ២០០៦។ កត្តាទាំងនេះ បានធ្វើឲ្យតួអង្គ ឬស្ថាប័ននីមួយៗទទួលបាននូវចំនួនផ្សេងគ្នានៃករណីវិវាទដីធ្លី *(សូមមើលផ្នែក តួអង្គ និងស្ថាប័ននីមួយៗ ព្រោះថា តួអង្គនិងស្ថាប័នទាំងនេះទទួលបាននូវចំនួនផ្សេងគ្នានៃករណីវិវាទដីធ្លីដែលលើកឡើងខាងលើ)។*

## ២.២ អត្ថប្រយោជន៍ និងបញ្ហាប្រឈមនានានៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

គេសង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួនដែលស្ថាប័នរដ្ឋាភិបាលកំពុងជួបប្រទះ ក្នុងការដោះស្រាយវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា។ ចំពោះ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និងមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ មានបញ្ហាប្រឈមមួយគឺថា សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការពង្រឹង និងពង្រីកប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានភាពយឺតយ៉ាវ ដែលឈានទៅដល់ការមិនមានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តការងារឲ្យបានរលូន។[26] ពាក់ព័ន្ធនឹងគណៈកម្មការសុរិយោដី គេសង្កេតឃើញថា គណៈកម្មការនេះនៅគ្រប់កម្រិតហាក់បីដូចជា មានការខ្វះខាតនូវធនធានមនុស្ស និងធនធានថវិកាដែលចាំបាច់សម្រាប់ដោះស្រាយនូវវិវាទនានា។ ហេតុដូចនេះ កត្តាទាំងនេះចូលរួមចំណែកធ្វើឲ្យមានការអូសបន្លាយនូវដំណើរការផ្សះផ្សា។[27] បើទោះបីជា គណៈកម្មការសុរិយាដី ហាក់បីដូចជា មានភាពប្រសើរក្នុងការដោះស្រាយវិវាទដីធ្លីដែលមានទំហំដីតូចក៏ដោយ គណៈកម្មការសុរិយាដីហាក់បីដូចជាមានការលំបាកបន្តិចក្នុងការដោះស្រាយករណីវិវាទដែលមានលក្ខណៈស្មុគស្មាញ ជាពិសេសករណីវិវាទណាដែលពាក់ព័ន្ធទៅនឹងភាគីជម្លោះច្រើន និងជម្លោះដីធ្លីដែលមានទំហំដីធំ។[28] ពាក់ព័ន្ធនឹងកម្មវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់អង្គការ

---

[26] Ministry of Justice, Report to the Minister of the Ministry of Justice, No. 02 STY/14 dated January 14, 2014.

[27] Manami Sekiguchi and Naomi Hatsukano, "Land Conflict and Land Registration in Cambodia," in *Land and Post-Conflict Peacebuilding*, ed. J.Unruh and R.C. Williams. (London: Earthscan, 2013) 437-448, p. 446 accessed on June 25, 2015, URL: http://www.environmentalpeacebuilding.org/assets/Documents/LibraryItem-000-Doc-165.pdf

[28] World Bank, Centre for Advanced Study and GTZ, "Towards Institutional Justice? A Review of the Work of Cambodia's Cadastral Commission in Relation to Land Dispute Resolution," p. xiv (2006), accessed on June 25, 2015, URL: http://siteresources.worldbank.org/INTJUSFORPOOR/Resources/TowardsInstitutionalJustice.pdf

ADHOC គេសង្កេតឃើញថា កង្វះនូវមូលនិធិរយៈពេលវែងបានធ្វើឲ្យមានបញ្ហាប្រឈមដ៏ចំបងមួយក្នុងការធានាឲ្យបាននូវនិរន្តរភាពរបស់កម្មវិធីនេះនាពេលអនាគត។[29] នៅក្នុងន័យនេះ ទាំងស្ថាប័នរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ហាក់បីដូចជាជួបនូវបញ្ហាប្រឈមពាក់ព័ន្ធនឹងកង្វះខាតផ្នែកហិរញ្ញវត្ថុ ដែលទំនងជាឧបសគ្គក្នុងការអនុវត្តឲ្យកាន់តែរលូននៃដំណើរការដោះស្រាយវិវាទដីធ្លី។

ទោះបីជា មានបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការក៏ដោយ គេសង្កេតឃើញថា ការប្រើប្រាស់យន្តការនេះបានផ្តល់នូវអត្ថប្រយោជន៍មួយចំនួនផងដែរ។ អត្ថប្រយោជន៍ទីមួយគឺ ភាគីជម្លោះមានការចំណាយតិច ប្រសិនបើប្រៀបធៀបទៅនឹងការចំណាយនៃដំណើរការរឿងក្តី តាមរយៈប្រព័ន្ធតុលាការ។ ការណ៍នេះ គឺដោយសារតែការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនតម្រូវឲ្យមានការរៀបចំឯកសារច្រើននោះទេ ហេតុដូចនេះការចំណាយក៏ទាប។[30] អត្ថប្រយោជន៍ទីពីរគឺ ភាគីជម្លោះប្រើប្រាស់ពេលវេលាតិចក្នុងការដោះស្រាយវិវាទ ប្រសិនបើប្រៀបធៀបទៅនឹងពេលវេលាដែលប្រើប្រាស់សម្រាប់ដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ។ ការណ៍នេះ ដោយសារតែវិធីសាស្រ្ត (សន្ធានកម្ម ការផ្សះផ្សា និងមជ្ឈត្តកម្ម) នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អនុញ្ញាតឲ្យភាគីធ្វើការជ្រើសរើសនូវពេលវេលាដែលសមស្របសម្រាប់ភាគី (រាប់បញ្ចូលទាំងភាគីអព្យាក្រឹត្យទីបី) ដោយមិនតម្រូវឲ្យភាគីត្រូវគោរពតាមពេលវេលាកំណត់ដូចនៅតុលាការទេ។[31] អត្ថប្រយោជន៍មួយទៀតគឺថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហាក់បីដូចជា បង្កើតនូវទំនាក់ទំនងប្រសើររវាងភាគី ពីព្រោះថា វាផ្តល់ជូននូវវេទិកាសម្រាប់ភាគីជម្លោះ ដើម្បីពិភាក្សានូវបញ្ហាដែលមិនទាន់ដោះស្រាយ ឬក៏បញ្ហាដែលមានការយល់ច្រឡំនឹងគ្នា នៅក្នុងបរិយាកាសដែលមិនមានភាពតានតឹង។ ការណ៍នេះ ទំនងជាអាចជួយឲ្យភាគីឈានទៅដល់កិច្ចព្រមព្រៀងយោគយល់គ្នាទៅវិញទៅមកដែលផ្តល់ជូននូវដំណោះស្រាយឈ្នះ-ឈ្នះសម្រាប់ភាគីទាំងពីរ។[32]

# ៣. ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសហ្វីលីពីន

## ៣.១ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ

ជាជាងដើរតួនាទីជាសន្ធានការី/អ្នកផ្សះផ្សា សម្រាប់ការដោះស្រាយវិវាទដីធ្លី អង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅក្នុងប្រទេសហ្វីលីពីន មាននិន្នាការចូលរួមពាក់ព័ន្ធនៅក្នុងបញ្ហាដីធ្លីដែលធ្វើការចូលរួមចាប់ពីសកម្មភាពនយោបាយរហូតដល់ដើរតួនាទីភ្ជាប់នូវទំនាក់ទំនងរវាងប្រជាជន និងរដ្ឋាភិបាលដែលនៅខ្វះ

[29] Gerben Willem van Dijk, Access to Justice: An Assessment of the Government and ADHOC Alternative Dispute Resolution Systems in Cambodia, 2014, p. 29. [Draft version]
[30] Goldberg ,"Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum", p.5, accessed on 29 June, 2015, URL: http://digitalcommons.pepperdine.edu/cgi/viewcontent.cgi?article=1261&context=drlj
[31] Ibid.
[32] Goldberg ,"Online Alternative Dispute," p. 5

ចន្លោះ។[33] ឧទាហរណ៍ក្នុងពេលដោះស្រាយវិវាទដីធ្លី អង្គការមិនមែនរដ្ឋាភិបាលព្យាយាមបង្កើតនូវកិច្ចពិភាក្សារវាងភាគីដែលពាក់ព័ន្ធនឹងវិវាទ ដើម្បីបង្កើនទំនាក់ទំនង និងកសាងសន្តិភាព។[34] អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ធ្វើការគាំទ្រដល់ក្រុមសហគមន៍នានា តាមរយៈការផ្តល់ជូននូវធនធានហិរញ្ញវត្ថុ ការតស៊ូមតិ និងការកសាងសមត្ថភាព។[35] ករណីនេះ ហាក់ដូចជា អង្គការមិនមែនរដ្ឋាភិបាលនៅហ្វីលីពីន ព្យាយាមពង្រឹងសមត្ថភាពដល់សហគមន៍រងគ្រោះនានា ដើម្បីមានសមត្ថភាពក្នុងតស៊ូមតិដោយខ្លួនពួកគាត់ផ្ទាល់ ដើម្បីឲ្យមានការដោះស្រាយវិវាទនានា។

## ៣.២ យន្តការរបស់រដ្ឋាភិបាល

ក្រៅពីអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមពាក់ព័ន្ធក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រដ្ឋាភិបាលប្រទេសហ្វីលីពីន បានបង្កើតនូវយន្តការដើម្បីដោះស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការ។ យន្តការទាំងនោះរួមមាន៖

- **ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម (The Department of Agrarian Reform Adjudication Board "DARAB")** ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ និងបទបញ្ជាប្រតិបត្តិ លេខ១២៩-A។ ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម មានតួនាទីដ៏សំខាន់មួយ តាមរយៈការបង្កើតនូវវេទិកា សម្រាប់ការដោះស្រាយវិវាទដីធ្លីនានា។[36] ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម ទទួលយកករណីវិវាទដីធ្លីទាំងឡាយ តាមរយៈពាក្យបណ្តឹងជាលាយល័ក្ខអក្សរ ឬពាក្យបណ្តឹងផ្ទាល់មាត់ ហើយករណីវិវាទដីធ្លីទាំងនោះ ត្រូវបានដោះស្រាយតាមរយៈសន្ធានកម្ម (mediation) នៅចំពោះមុខគណៈកម្មាធិការកំណែទម្រង់កសិកម្មថ្នាក់ស្រុក (Barangay [or District] Agrarian Reform Committee "BARC")។[37] ប្រធានរបស់គណៈកម្មការកំណែទម្រង់កសិកម្មថ្នាក់ស្រុក ទទួលខុសត្រូវចំបងក្នុងការដោះស្រាយជម្លោះតាមរយៈការធ្វើសន្ធានកម្ម។ ប្រសិនបើការធ្វើសន្ធានកម្ម

---

[33] USAID, *Philippines-Property Rights and Resource Governance,* (Philippines, 2011), 10, accessed on June 25, 2015, URL: http://usaidlandtenure.net/sites/default/files/country-profiles/full-reports/USAID_Land_Tenure_Philippines_Profile.pdf

[34] Seneca Pellano, "Rapporteur's Report: Panel 2A- Challenges and Dilemmas of Advocacy: Addressing Corporate Land Acquisition (B)" (report documented at the International Conference on Contested Access to Land in the Philippines and Indonesia: How Can the Rural Poor [Re]gain Control?, University of the Philippines Diliman, February 16-17, 2015), accessed on June 26, 2015, URL: http://calpi.up.edu.ph/?p=272

[35] USAID, *Philippines-Property Rights and Resource Governance,* p. 10

[36] Institute of Developing Economies, *Dispute Resolution Mechanisms in the Philippines* (Philippines, 2002), 21.យោងតាមប្រភពឯកសារនេះ DARAB មានសមត្ថកិច្ចទៅលើវិវាទណាដែលមានទំនាក់ទំនងនឹងដីកសិកម្ម ព្រមទាំង បញ្ហាដីធ្លីផ្សេងទៀតដែលពាក់ព័ន្ធនឹងម្ចាស់ដី និងអ្នកជួល ឬក៏ រវាងក្រុមសហការ និងអ្នកជួល។ ការិយាល័យរបស់ DARAB មានទំនាក់ទំនងជាមួយនឹង នាយកដ្ឋានកំណែទម្រង់កសិកម្ម (DAR)។

[37] BARC រួមមាន សមាជិកចំនួន ១០ ដែលតំណាងឲ្យ នាយកដ្ឋានកំណែទម្រង់កសិកម្ម នាយកដ្ឋានបរិស្ថាន និងធនធានធម្មជាតិ ធនាគារដី និងអង្គភាព កសិកម្មផ្សេងៗទៀត, Ibid.

មិនបានជោគជ័យ ករណីវិវាទត្រូវគេយកទៅធ្វើមជ្ឈត្តកម្ម (arbitration) នៅចំពោះមុខអ្នកវិនិច្ឆ័យកំណែទម្រង់កសិកម្មថ្នាក់ខេត្ត (Provincial Agrarian Reform Adjudicator "PARAD")។[38]

បន្ទាប់ពីធ្វើសវនាការ អ្នកវិនិច្ឆ័យកំណែទម្រង់កសិកម្មថ្នាក់ខេត្ត ចេញនូវកិច្ចព្រមព្រៀង ឬសេចក្តីសម្រេចអជ្ញាកណ្តាល។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចដែលចេញដោយអ្នកវិនិច្ឆ័យកំណែទម្រង់កសិកម្មថ្នាក់ខេត្ត អាចត្រូវបានគេប្តឹងតវ៉ាទៅកាន់ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម។[39] ការធ្វើបណ្តឹងឧទ្ធរណ៍បន្តទៀត អាចត្រូវផ្ញើជូនសាលាឧទ្ធរណ៍។ ប៉ុន្តែ ប្រសិនបើមិនមានបណ្តឹងឧទ្ធរណ៍ទេនោះ សេចក្តីសម្រេចក្លាយជាស្ថាពរ និងអនុវត្តដោយនគរបាល។[40] យោងតាមរបាយការណ៍របស់សម្ព័ន្ធអង្គការអាស៊ីសម្រាប់កំណែទម្រង់កសិកម្ម និងការអភិវឌ្ឍន៍ជនបទ (Asian NGO Coalition for Agrarian Reform and Rural Development "ANGOC") ដែលមានចំណងជើងថា "ការត្រួតពិនិត្យតាមដានកំណែទម្រង់ដីធ្លីរបស់អង្គការសង្គមស៊ីវិលនៅអាស៊ីនៅឆ្នាំ ២០១២" (CSO Land Reform Monitoring in Asia in 2012) ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្មទទួលបានសំណុំរឿងវិវាទចំនួន ១៤000 ករណី ដែល៩៦%នៃករណីជម្លោះត្រូវបានដោះស្រាយ។[41] គួរកត់សម្គាល់ផងដែរថា ការកើនឡើងករណីដែលទទួលដោយ ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម គឺដោយសារតែស្ថាប័ននេះ បានប្តូរការផ្តោតការយកចិត្តទុកដាក់ពីការដោះស្រាយវិវាទពាក់ព័ន្ធនឹងការដកហូតដីដើម្បីបម្រើប្រយោជន៍សាធារណៈ (land acquisition) មកជាការដោះស្រាយវិវាទដីឯកជន (private land) ចាប់តាំងពីឆ្នាំ ២000 មក។[42] ទោះបីជាយ៉ាងណាក៏ដោយ គួរតែមានទិន្នន័យ និងការពន្យល់បន្ថែមទៀត ដើម្បីបញ្ជាក់បន្ថែមពីមូលហេតុដែលក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម បានដោះស្រាយករណីវិវាទបានច្រើន។

- **គណៈកម្មការដោះស្រាយបញ្ហាដីធ្លី (The Commission on the Settlement of Land Problems"COSLAP")** ត្រូវបានបង្កើតជាស្ថាប័នដែលមានអំណាចពាក់កណ្តាលតុលាការ (quasi-judicial body) ដោយបទបញ្ជាប្រតិបត្តិលេខ ៥៦១ នៅក្នុងឆ្នាំ ១៩៧៩។ គណៈកម្មការដោះស្រាយបញ្ហាដីធ្លី មានតួនាទីសំខាន់ក្នុងការដោះស្រាយបញ្ហាដីធ្លីតាមរយៈវិធីសាស្ត្រសន្ធានកម្ម/ការផ្សះផ្សា។[43] ស្ថាប័ននេះ មានការទទួលខុសត្រូវចំបងៗក្នុងការដោះស្រាយរាល់ប្រភេទនៃ

---

38 Ibid.

39 ក្រុមប្រឹក្សាភិបាល DARAB រួមមាន លេខាធិការរបស់ DAR អនុលេខាធិការចំនួន ២រូប និង ជំនួយការលេខាធិការចំនួន ១រូប, Ibid។

40 Ibid.

41 ANGOC, *CSO Land Reform Monitoring in Asia*, (Philippines, 2012), 137-152, accessed on June 25, 2015, URL: http://www.landcoalition.org/sites/default/files/documents/resources/CSO_Land_Monitoring_Full.pdf

42 Ibid, p.144

43 Department of Justice, 2009 Department of Justice Annual Report, 26, accessed on June 17, 2015, URL: https://www.doj.gov.ph/files/2009Annual.pdf

វិវាទដីធ្លីដែលពាក់ព័ន្ធនឹងៈ អ្នកកាន់កាប់ដីធ្លី/អ្នកកាន់កាប់ដីធ្លីខុសច្បាប់ និងម្ចាស់ក្រុមហ៊ុនទទួលបានសម្បទានចំការកៅស៊ូ អ្នកកាន់កាប់ដីធ្លី/អ្នកកាន់កាប់ដីធ្លីខុសច្បាប់ និងអ្នកដែលទាមទារដីសាធារណៈ ព្រមទាំងបញ្ហាដីធ្លីដទៃទៀតផ្សេងទៀតដែលមានលក្ខណៈស្រដៀងនេះ (ឧ. ការឈូសឆាយលំនៅដ្ឋាន) ជាដើម។[44]

នៅពេលភាគីជម្លោះណាមួយរៀបចំឯកសារពាក្យបណ្តឹងបញ្ជូនទៅកាន់ គណៈកម្មការដោះស្រាយបញ្ហាដីធ្លី ដំណើរការដោះស្រាយវិវាទនឹងចាប់ផ្តើម។ គណៈកម្មការសន្ទានកម្ម (mediation committee) ដែលរួមមានតំណាងមកពីស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធផ្សេងៗ ទទួលខុសត្រូវធ្វើសន្ទានកម្មវិវាទទាំងនោះ។[45] ប្រសិនបើការធ្វើសន្ទានកម្មមិនទទួលបានជោគជ័យ សវនាការលើសំណុំរឿងនោះនឹងកើតឡើង ដើម្បីធ្វើមជ្ឈត្តកម្មលើវិវាទនោះ។ ដោយសារតែគណៈកម្មការដោះស្រាយបញ្ហាដីធ្លី មិនត្រូវបានគ្រប់គ្រងដោយវិធាននៃនិតិវិធី និងភស្តុតាង (rules of procedures and evidence) ជាហេតុធ្វើឲ្យគណៈកម្មការនេះមានភាពងាយស្រួលក្នុងការរៀបចំនូវកិច្ចព្រមព្រៀងទៅលើនិតិវិធីសម្រាប់ពន្លឿនដំណើរការដោះស្រាយវិវាទ។[46] ទាំងភាគី និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី ត្រូវតែអនុវត្តទៅតាម (ឬមានកាតព្វកិច្ចអនុវត្តតាមសេចក្តីសម្រេច) សេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយបញ្ហាដីធ្លី។ ទោះបីជាយ៉ាងណាក៏ដោយហាក់ដូចជាមានការលំបាក ក្នុងការអនុវត្តនូវសេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយបញ្ហាដីធ្លី ដោយសារតែស្ថាប័នរដ្ឋាភិបាលផ្សេងៗមាននិតិវិធីផ្ទាល់ខ្លួនសម្រាប់ធ្វើការស៊ើបអង្កេតវិវាទ ហើយការណ៍នេះ មិនអនុញ្ញាតឲ្យមានការអនុវត្តដោយស្វ័យប្រវត្តិនៃបទបញ្ជារបស់គណៈកម្មការដោះស្រាយបញ្ហាដីធ្លីឡើយ។[47]

បើតាមរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋានយុត្តិធម៌នៅឆ្នាំ២០០៩ គណៈកម្មការដោះស្រាយបញ្ហាដីធ្លី បានដោះស្រាយសំណុំរឿងចំនួន ១៨០៥ ករណី (រួមបញ្ចូលទាំងករណីដែលបានបញ្ជូនមកពីឆ្នាំមុន) ដែលចំនួនសំណុំរឿងដែលបានដោះស្រាយនេះ បានលើសគោលដៅដែលគណៈកម្មការដោះស្រាយបញ្ហាដីធ្លីកំណត់ដោះស្រាយត្រឹម ១៧០០ករណី សម្រាប់ឆ្នាំ ២០០៩។ ការណ៍នេះ ទំនងជាដោយសារតែគណៈកម្មការដោះស្រាយបញ្ហាដីធ្លីបានព្យាយាមពង្រឹងនូវដំណើរការសន្ទានកម្ម និងវិធីសាស្ត្រផ្សេងៗទៀតក្នុងការដោះស្រាយជម្លោះដីធ្លី។[48]

## ៤. សេចក្តីសន្និដ្ឋាន

44 Institute of Developing Economies, *Dispute Resolution*, p. 25
45 Ibid.
46 Ibid.
47 Ibid.
48 Department of Justice, 2009 Department of Justice Annual Report, 26

ទោះបីជា មានការកើនឡើងនូវការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា គេសង្កេតឃើញថា ស្ថាប័នរដ្ឋាភិបាលនៅតែជាតួអង្គសំខាន់សម្រាប់ការដោះស្រាយវិវាទដីធ្លីទាំងឡាយចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។ ឧទាហរណ៍ គណៈកម្មការសុរិយោដី ហាក់បីដូចជាបានដោះស្រាយករណីវិវាទដីធ្លីគួរឲ្យកត់សម្គាល់ (២៧៤២ ករណី [៤៤%] នៃ ៦២២៤ករណី ដែលទទួលបានសរុប) តាំងពីគណៈកម្មការនេះបង្កើតឡើង។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតទៅលើផ្នែកមួយចំនួននៃស្ថាប័នរដ្ឋាភិបាលទាំងនេះ គឺជាតម្រូវការចំបាច់ដើម្បីពន្លឿនការដោះស្រាយចំពោះករណីវិវាទដីធ្លីផ្សេងៗទៀត។

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើបញ្ហាដីធ្លីនៅក្នុងប្រទេសហ្វីលីពីន ដើរតួនាទីជាភ្នាក់ងារ ដើម្បីភ្ជាប់នូវទំនាក់ទំនងរវាងប្រជាជន និងរដ្ឋាភិបាល តាមរយៈការបង្កើតឲ្យមានវេទិកាពិភាក្សាក្នុងចំណោមភាគីដែលពាក់ព័ន្ធនឹងវិវាទ ដើម្បីបង្កើននូវទំនាក់ទំនងរវាងភាគីទាំងនោះ (ឧ.ការសម្របសម្រួលវិវាទដែលមានលក្ខណៈមិត្តភាព)។ ស្រដៀងគ្នានឹងរដ្ឋាភិបាលប្រទេសកម្ពុជាដែរ រដ្ឋាភិបាលប្រទេសហ្វីលីពីនបានបង្កើតនូវស្ថាប័នមួយចំនួនដើម្បីដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការរួមមាន៖ ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម និងគណៈកម្មការដោះស្រាយបញ្ហាដីធ្លី។ ក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម ហាក់បីដូចជាបំពេញការងារបានល្អក្នុងការដោះស្រាយវិវាទនានាដែលខ្លួនបានទទួល ព្រោះថា ស្ថាប័ននេះ បានដោះស្រាយវិវាទប្រមាណជា ៩៦%នៃវិវាទសរុបដែលទទួលបាន។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវតែមានព័ត៌មានចាំបាច់បន្ថែម ដើម្បីឲ្យដឹងថាតើមានមូលហេតុអ្វីខ្លះបានជាក្រុមប្រឹក្សាភិបាលវិនិច្ឆ័យនៃនាយកដ្ឋានកំណែទម្រង់កសិកម្ម ទទួលបាននូវភាពជោគជ័យក្នុងការដោះស្រាយករណីវិវាទដោយមានចំនួនច្រើន។

ជាទូទៅ ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសហ្វីលីពីន ស្ថាប័នរដ្ឋាភិបាល គឺជាតួអង្គចំបងក្នុងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ។ អត្ថប្រយោជន៍នៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការរួមមាន៖ (១) ភាគីជម្លោះចំណាយថវិកាតិចក្នុងដំណើរការដោះស្រាយសំណុំរឿង (២) ភាគីជម្លោះចំណាយពេលវេលាតិចក្នុងដំណើរការដោះស្រាយសំណុំរឿង និង(៣) ភាគីអាចថែរក្សាទំនាក់ទំនង។

# គន្ថនិទ្ទេស

ANGOC. 2012. *CSO Land Reform Monitoring in Asia*. Accessed on June 25, 2015.

http://www.landcoalition.org/sites/default/files/documents/resources/CSO_Land_Monitoring_Full.pdf

ADHOC. 2013. "Result of ADR Section in 2013." Accessed on June 22, 2015. http://www.adhoc-cambodia.org/?p=4374

Department of Justice. 2009. Department of Justice Annual Report in 2009. Accessed on June 17, 2015. https://www.doj.gov.ph/files/2009Annual.pdf

Gerben, Willem van Dijk. 2014. Access to Justice: An Assessment of the Government and ADHOC Alternative Dispute Resolution Systems in Cambodia. [Draft version]

Jordan, Goldberg. 2014. "Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum." Accessed on 29 June, 2015. http://digitalcommons.pepperdine.edu/cgi/viewcontent.cgi?article=1261&context=drlj

Ramage, Ian, Pictet, Gabriel, Chhy Sophearith, and Jorde Alanna. 2008. *Somroh Somruel& Violence Against Women. (* Domrei Research and Consulting).

Kong, Phallack. 2012. "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform", in The Introduction to Cambodian Law, (Konrad-Adenauer-Stiftung, 2012). Accessed on June 08, 2015. http://www.kas.de/wf/doc/kas_31083-1522-1-30.pdf?120720080906

Manami, Sekiguchi and Naomi Hatsukano. 2013. "Land Conflict and Land Registration in Cambodia," in *Land and Post-Conflict Peacebuilding,* ed. J.Unruh and R.C. Williams. (London: Earthscan, 2013). Accessed on June 25, 2015. http://www.environmentalpeacebuilding.org/assets/Documents/LibraryItem-000-Doc-165.pdf

Melissa, Lewis and Les McCrimmon. 2005. "The Role of ADR Process in the Criminal Justice System: A view from Australia" ( Paper presented at At ALRAESA Conference, Entebbe, Uganda 4-8 September, 2005). Accessed on June 08, 2015. http://www.justice.gov.za/alraesa/conferences/2005uganda/ent_s3_mccrimmon.pdf

Ministry of Justice. 2014. *Report to the Minister of the Ministry of Justice*, No. 02 STY/14 dated January 14, 2014.

NGO Forum. 2013. *Statistical Analysis of Land Disputes in Cambodia* (Phnom Penh). Accessed on June 08, 2015. http://www.ngoforum.org.kh/administrator/components/com_ngoforum/files/8c28b5c3c50045d8aa923b5a62247ee0-Layout-Land-dispute-report-2013-Eng.pdf

Inter-ministerial Prakas No. 85Rbk/MOJ/MOI/06

Institute of Developing Economies. 2002. *Dispute Resolution Mechanisms in the Philippines* (Philippines, 2002). Accessed on June 17, 2015. http://www.ide.go.jp/English/Publish/Download/Als/pdf/18.pdf

Royal Decree. 2006. Establishment of National Authority to Settle Land Dispute, NS/RKT/0206/097 February 26 2006.

Seneca, Pellano. 2015. "Rapporteur's Report: Panel 2A- Challenges and Dilemmas of Advocacy: Addressing Corporate Land Acquisition (B)" (report documented at the International Conference on Contested Access to Land in the Philippines and Indonesia: How Can the Rural Poor [Re]gain Control?, University of the Philippines Diliman, February 16-17, 2015). Accessed on June 26, 2015. http://calpi.up.edu.ph/?p=272

Steven, Austermiller. 2012. "Cambodian Alternative Dispute Resolution," in The Introduction to Law (Konrad-Adenauer-Stiftung). http://www.kas.de/wf/doc/kas_31083-1522-1-30.pdf?120720080906

Sub Decree. 2002. Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002.

The Asia Foundation. 2005. Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution, by Kim Ninh and Roger Henke. Access on 29 June, 2015. https://asiafoundation.org/resources/pdfs/CBCCSurvey.pdf

UNDP. 2010. Cambodia Operation manual for commune dispute resolution committee (CDRC), (UNDP-Cambodia).

USAID. 2011. *Philippines-Property Rights and Resource Governance,* (Philippines). Accessed on June 25, 2015. http://usaidlandtenure.net/sites/default/files/country-profiles/full-reports/USAID_Land_Tenure_Philippines_Profile.pdf

World Bank, Centre for Advanced Study and GTZ. 2006. "Towards Institutional Justice? A Review of the Work of Cambodia's Cadastral Commission in Relation to Land Dispute Resolution." Accessed on June 25, 2015. http://siteresources.worldbank.org/INTJUSFORPOOR/Resources/TowardsInstitutionalJustice.pdf

Yrigoyen, Fajardo, Kong Rady and Phan Sin. 2005. *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples.*